


ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជា នៅចុងឆ្នាំ២០២១

បើទោះជាប្រឈមនូវបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាមួយចំនួនដូចជា ភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងចិន, ភាពមិនប្រាកដប្រជានៃការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប, ការឡើងកំដៅនៃភូមិសាស្ត្រនយោបាយ និងការបន្តនិន្នាការគោលនយោបាយគាំពារនិយមជាដើម, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០១៩ នៅតែបន្តសម្រេចបានកំណើនល្អក្នុងអត្រា ៧,១% ។ កំណើនល្អនេះត្រូវបានគាំទ្រដោយសារការបន្តរីកចម្រើននៃវិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម ជាពិសេសអនុវិស័យសំណង់, អនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ និងអនុវិស័យលក់ដុំ-រាយ ។ ទោះជាយ៉ាងនេះក្តី កម្ពុជានៅបន្តជួបប្រទះបញ្ហាប្រឈមជារចនាសម្ព័ន្ធសំខាន់ៗចំនួន ២ គឺ ភាពប្រកួតប្រជែងនៅមានកម្រិត និងភាពយឺតយ៉ាវនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច ។ ជាការឆ្លើយតប រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគោលនយោបាយផ្សេងៗ មានដូចជា÷ ការជួយសម្រួលក្នុងការកាត់បន្ថយថ្លៃដើម, ពេលវេលា និងបង្កើនភាពងាយស្រួលដល់ការធ្វើអាជីវកម្ម ដោយបន្តពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម, ការកាត់បន្ថយថ្លៃ និងធានាស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី, ការកាត់បន្ថយថ្លៃដឹកជញ្ជូន និងឡូជីស្ទីក, ការបង្កើនការតភ្ជាប់ឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបង្កើនការបណ្តុះបណ្តាលជំនាញ, ការកាត់បន្ថយកម្រៃក្រៅផ្លូវការ, ការលើកកម្ពស់សេវាបង់ពន្ធ, ការកាត់បន្ថយការធ្វើសវនកម្មពន្ធដារត្រួតគ្នា និងការជំរុញការប្រកួតប្រជែង ដោយស្មើភាព, ការអនុម័តច្បាប់វិនិយោគថ្មី, ច្បាប់ស្តីពីការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស និងច្បាប់ស្តីពីការប្រកួតប្រជែង, ការរៀបចំផែនការមេដើម្បីអភិវឌ្ឍខេត្តព្រះសីហនុ

ឱ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសតំរូវពហុបំណង, ការបន្តលើកទឹកចិត្តផ្នែកសារពើពន្ធ ដើម្បីលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ការស្វែងរកទីផ្សារក្រៅស្រុកបន្ថែម ទាំងទ្វេភាគី និង ពហុភាគី តាមរយៈការពង្រីកទីផ្សារក្រៅប្រទេសទៅក្នុងប្លុកពាណិជ្ជកម្មថ្មីៗ, ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការដឹកនាំ និងការអនុវត្តគោលនយោបាយ និងវិធានការនានា, ការបង្កើនប្រសិទ្ធភាពនៃការសម្របសម្រួលស្ថាប័ន ឬមុខងារ តាមរយៈការធ្វើវិចារណកម្មមុខងារ និងភារកិច្ច ព្រមទាំងការលើកកម្ពស់ភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន; ការបង្កើនការអភិវឌ្ឍធនធានមនុស្ស ដោយផ្តោតសំខាន់ទាំងបរិមាណ និងគុណភាព។

ក្នុងឆ្នាំ ២០២០ ពិភពលោកទាំងមូលបានជួបប្រទះនឹងវិបត្តិសុខភាពសាធារណៈជាសកល ដែលបណ្ដាលមកពីការរីករាលដាលយ៉ាងឆាប់រហ័សនៃជំងឺកូវីដ-១៩ រហូតឈានទៅដល់ការបិទប្រទេស, ការបិទទីក្រុង, ការរឹតត្បិតការធ្វើដំណើរ និងការដាក់ចេញនូវវិធានការម៉ឺងម៉ាត់មួយចំនួនទៀត សំដៅទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ជាលទ្ធផល វិធានការទាំងនោះបានបន្ថែមសម្ពាធ និងបង្អាក់សកម្មភាពផលិតកម្ម, ការផ្គត់ផ្គង់, ការប្រើប្រាស់ និងការវិនិយោគ ដែលបានរុញច្រានកំណើនសេដ្ឋកិច្ចសកលក្នុងឆ្នាំ ២០២០ ឱ្យធ្លាក់ចុះគួរឱ្យកត់សម្គាល់ ។ មិនខុសពីបណ្ដាប្រទេសនានាលើសកលលោកឡើយ, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២០ ក៏បានទទួលរងផលប៉ះពាល់ពីវិបត្តិសកលនេះផងដែរ និងជារួមត្រូវបានវាយតម្លៃថាសម្រេចបានកំណើនអវិជ្ជមាន ក្នុងអត្រា -៣,១% ដោយសារការធ្លាក់ចុះនៃវិស័យសេវាកម្ម និងវិស័យឧស្សាហកម្ម ខណៈវិស័យកសិកម្មនៅរក្សាបានកំណើនវិជ្ជមាន ។ ក្នុងនោះ វិស័យសេវាកម្មមានកំណើនអវិជ្ជមាន ក្នុងអត្រា ៦,៧% ដោយសារការធ្លាក់ចុះយ៉ាងគំហុកនៃអនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន និងកំណើនអវិជ្ជមាននៃអនុវិស័យអចលនទ្រព្យ និងអនុវិស័យផ្សេងទៀតដែលគាំទ្រដល់វិស័យទេសចរណ៍។ ជាមួយគ្នានេះ វិស័យឧស្សាហកម្មត្រូវបានវាយតម្លៃថាមានកំណើនអវិជ្ជមាន ក្នុងអត្រា ១,២% ដែលបណ្ដាលមកពីការធ្លាក់ចុះនៃអនុវិស័យកាត់ដេរ និងអនុវិស័យសំណង់ ខណៈអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរនៅរក្សាបានកំណើនខ្ពស់ ។ ទោះជាយ៉ាងនេះក្តី, វិស័យកសិកម្មត្រូវបានវាយតម្លៃថាមានកំណើនវិជ្ជមានក្នុងអត្រា ០,៥% ដែលគាំទ្រដោយកំណើនទាបនៃអនុវិស័យដំណាំ និងការងើបឡើងវិញនៃអនុវិស័យចិញ្ចឹមសត្វ និងអនុវិស័យនេសាទ បន្ទាប់ពីកំណើនអវិជ្ជមានក្នុងឆ្នាំ ២០១៩។

ជាមួយនឹងកំណើនអវិជ្ជមាននេះ ផសស ថ្លៃបច្ចុប្បន្នបានធ្លាក់ចុះមក ១០៩ ០៦២ ប៊ីលានរៀល និងធ្វើឱ្យ ផសស សម្រាប់មនុស្សម្នាក់ថមថយមកប្រមាណ ១ ៦៥៣ ដុល្លារអាមេរិក។ អតិផរណាមានការកើនឡើងបន្តិច ប៉ុន្តែស្ថិតក្នុងកម្រិតគ្រប់គ្រងបានក្នុងអត្រា ២,៩% ក្នុងឆ្នាំ ២០២០ ធៀបនឹង ១,៨% ក្នុងឆ្នាំ ២០១៩ ដោយសារការកើនឡើងនៃតម្រូវការ (Demand Shock) ម្ហូបអាហារ និងផលិតផលផ្សេងទៀតនៅលើទីផ្សារ ស្របពេលដែលសមត្ថភាព

ផ្គត់ផ្គង់មានការថមថយ, ដោយឡែកថ្លៃដឹកជញ្ជូនមានការធ្លាក់ចុះ ដោយសារការធ្លាក់ថ្លៃប្រេងលើទីផ្សារអន្តរជាតិ។ យ៉ាងណាមិញ អត្រាប្តូរប្រាក់នៅតែបន្តមានស្ថិរភាពក្នុងអំឡុងពេលវិបត្តិនេះ ក្នុងតម្លៃប្រមាណ ៤ ០៨០ រៀលក្នុងមួយដុល្លារអាមេរិក។

ដើម្បីឆ្លើយតបនឹងនិន្នាការខាងលើ ក៏ដូចជាគ្រប់គ្រងហានិភ័យផ្សេងៗ ដែលអាចកើតមាន រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការអន្តរាគមន៍សមស្រប និងទាន់ពេលវេលា តាមយៈការដាក់ចេញដោយប្រទាក់ក្រឡានូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយរចនាសម្ព័ន្ធ (structural policy) ដើម្បីសម្រេចឱ្យបានគោលបំណងរក្សាលំនឹងសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ច។

- **រក្សាលំនឹងសេដ្ឋកិច្ច÷** តាមរយៈការបន្តការពារ និងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, ការបន្តរក្សាលំនឹងសកម្មភាពអាជីវកម្ម និងការបន្តរក្សាលំនឹងជីវភាពប្រជាជន។
- **ជំរុញកំណើនសេដ្ឋកិច្ច÷** តាមរយៈការបន្តបង្កើនភាពប្រកួតប្រជែង, ការបន្តជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបន្តកែទម្រង់រចនាសម្ព័ន្ធ។